**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

លេខ ២៧០២ កសក

ថ្ងៃ ព្រហស្បតិ៍ ១រោច ខែ ផល្គុន ឆ្នាំ ចសំរឹទ្ធិស័ក ព.ស.២៥៦២

រាជធានីភ្នំពេញ, ថ្ងៃទី ២១ ខែ មីនា ឆ្នាំ២០១៩

# សេចក្តីណែនាំ
# ស្តីពីការប្រើប្រាស់យានយន្តគ្រប់ប្រភេទ
# របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

ក្នុងគោលបំណងដើម្បីធានាប្រសិទ្ធភាពក្នុងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ កិត្យានុភាព និងសេចក្តីថ្លៃថ្នូររបស់ក្រសួង ស្ថាប័នរដ្ឋ និងមន្ត្រីសាធារណៈ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សូមណែនាំដល់ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំក្រសួង ឯកឧត្តម លោក លោកស្រីជាថ្នាក់ដឹកនាំអង្គភាព ថ្នាក់ដឹកនាំមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត នាយកគម្រោង និងមន្ត្រីរាជការ អំពីការប្រើប្រាស់យានយន្ត ពិសេសយានយន្តជាកម្មសិទ្ធិរបស់រដ្ឋ ដូចខាងក្រោម៖

១-ត្រូវប្រើប្រាស់យានយន្តពាក់ស្លាកលេខរបស់រដ្ឋឱ្យបានត្រឹមត្រូវ បើកបរប្រកបដោយសេចក្តីថ្លៃថ្នូរ និងគោរពច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកឱ្យបានម៉ឺងម៉ាត់។

២-មិនត្រូវប្រើប្រាស់យានយន្ត ដែលមានពាក់ស្លាកលេខរដ្ឋក្រៅពីម៉ោងដែលខ្លួនត្រូវបំពេញការងារឡើយ ជាពិសេសកន្លែងសប្បាយគ្រប់ប្រភេទ រួមមានក្លឹបកំសាន្ត កន្លែងខារ៉ាអូខេ កន្លែងម៉ាស្សា។ល។

៣-មិនត្រូវអនុញ្ញាតឱ្យអ្នកដទៃប្រើប្រាស់យានយន្តដែលមានពាក់ស្លាកលេខរដ្ឋ ក្នុងគោលបំណងផ្សេងដែលមិនពាក់ព័ន្ធទៅនឹងការបំពេញភារកិច្ចរបស់ខ្លួនឡើយ។

៤-ត្រូវចាត់វិធានការ ឬប្តឹងស្ថាប័នមានសមត្ថកិច្ច ប្រសិនបើឃើញយានយន្តផ្សេងពាក់ស្លាកលេខដូចស្លាកលេខយានយន្តរបស់ខ្លួន។ ក្នុងករណីមិនអាចអនុវត្តបាន ត្រូវរាយការណ៍មកក្រសួង ដើម្បីក្រសួងស្នើសុំកិច្ចអន្តរាគមន៍ពីស្ថាប័នមានសមត្ថកិច្ច។

៥-ត្រូវដកហូតយកមកវិញទាំងអស់នូវស្លាកលេខយានយន្ត ដែលបានជម្រះចេញពីបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ឬត្រូវរៀបចំបែបបទប្រគល់ជូនស្ថាប័នមានសមត្ថកិច្ចគ្រប់គ្រងវិញ។

ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំក្រសួង ឯកឧត្តម លោក លោកស្រីជាថ្នាក់ដឹកនាំអង្គភាព មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត នាយកគម្រោង និងមន្ត្រីរាជការគ្រប់រូបនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ត្រូវអនុវត្តតាមសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាពខ្ពស់។

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**ចម្លងជូន៖**

-ឯកឧត្តម លោកជំទាវជាថ្នាក់ដឹកនាំក្រសួង

-ឯកឧត្តម លោក លោកស្រីជាថ្នាក់ដឹកនាំគ្រប់អង្គភាព

-លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត

-នាយកគ្រប់គម្រោង

"ដើម្បីអនុវត្ត"

-ឯកសារ កាលប្បវត្តិ